*ភ្នំពេញ, ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០១៣*

# សេចក្តីប្រកាសព័ត៌មានរបស់ការិយាល័យសហព្រះរាជអាជ្ញា ទាក់ទងនឹងការបញ្ជូន កាំង ហ្គេកអ៊ាវ ហៅ ឌុច ពីមន្ទីរឃុំឃាំង អ.វ.ត.ក ទៅកាន់ប្រព័ន្ធពន្ធនាគារជាតិ

នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ **កាំង ហ្គេកអ៊ាវ** ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតដោយអង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ នៅថ្ងៃដដែល សហព្រះរាជអាជ្ញា បានដាក់សំណើមួយសុំឲ្យអនុវត្តទោសស្របទៅតាមវិធាន១១៣(១) នៃវិធានផ្ទៃក្នុង។ សហព្រះរាជអាជ្ញាបានស្នើសុំថា៖

១.**កាំង ហ្គេកអ៊ាវ** ត្រូវបន្តនៅមន្ទីរឃុំឃាំង អ.វ.ត.ក រហូតដល់បញ្ចប់ការផ្តល់សក្ខីកម្មរបស់គាត់ក្នុងសំណុំរឿង ០០២ ដែលបានកំណត់ពេលរួចហើយ និង
២.ការផ្តល់ពន្ធនាគារសមស្រប ត្រូវបានកំណត់សម្រាប់ **កាំង ហ្គេកអ៊ាវ** នៅក្នុងប្រព័ន្ធពន្ធនាគារជាតិ។

អ.វ.ត.ក គឺជាតុលាការជាតិ ដែលស្ថិតនៅក្នុងប្រព័ន្ធច្បាប់របស់ប្រទេសកម្ពុជា ហើយអាជ្ញាធរកម្ពុជា គឺជាអ្នកទទួលខុសត្រូវចុងក្រោយសម្រាប់ការដាក់ពន្ធនាគាររាល់បុគ្គលទាំងអស់ដែលត្រូវបានផ្តន្ទាទោស និងបានប្រកាសទោសនៅ អ.វ.ត.ក ចំពោះទោសត្រូវជាប់ពន្ធនាគារ។

ឯកឧត្តមអគ្គនាយកពន្ធនាគារនៃក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលកម្ពុជា បានផ្តល់ជំនួយគ្រប់បែបយ៉ាងដល់សហព្រះរាជអាជ្ញា។ ទីកន្លែងសមស្រប ដែលអាចឲ្យ **កាំង ហ្គេកអ៊ាវ** នៅបាន គឺពន្ធនាគារខេត្តកណ្តាល។ បុគ្គលិកដែលជាសមាជិករបស់ការិយាល័យសហព្រះរាជអាជ្ញា បានទៅធ្វើទស្សនកិច្ចនៅពន្ធនាគារខេត្តកណ្តាល កាលពីខែមិថុនា ឆ្នាំ២០១២ និងខែឧសភា ឆ្នាំ២០១៣ ហើយបានធ្វើការត្រួតពិនិត្យទីកន្លែងដែលគេបានស្នើសម្រាប់ដាក់ **កាំង ហ្គេកអ៊ាវ** ។ ខណៈដែលបានទទួលស្គាល់អំពីការកម្រិតផ្សេងៗ នៅក្នុងការប្រតិបត្តិលក្ខខណ្ឌនៃពន្ធនាគារក្នុងស្រុក សហព្រះរាជអាជ្ញា ដោយមានមូលដ្ឋាននៅលើការអង្កេតសាកសួររបស់ខ្លួន បានធ្វើការសន្និដ្ឋានចុងក្រោយថា ទីកន្លែងពន្ធនាគារដែលគេបានស្នើសម្រាប់ដាក់ **កាំង ហ្គេកអ៊ាវ** នោះគឺជាពន្ធនាគារមួយ ដែលនឹងការពារផលប្រយោជន៍របស់គាត់បានល្អប្រសើរបំផុត។

កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៣ សហព្រះរាជអាជ្ញាបានធ្វើសំណើទៅអគ្គនាយកដ្ឋានពន្ធនាគារ នៃក្រសួងមហាផ្ទៃដើម្បីសុំផ្ទេរ **កាំង ហ្គេកអ៊ាវ** *ហៅ* **ឌុច** ទៅដាក់នៅពន្ធនាគារខេត្តកណ្តាល។ នៅពេលទន្ទឹមគ្នានេះ សហព្រះរាជ អាជ្ញាក៏បានសម្របសម្រួលផងដែរជាមួយអគ្គនាយកដ្ឋានពន្ធនាគារថា ទីកន្លែង និងស្ថានភាពនៃការឃុំខ្លួន **កាំង ហ្គេកអ៊ាវ** *ហៅ* **ឌុច**

នឹងមិនត្រូវប្រែប្រួលដែលនាំឲ្យប៉ះពាល់ដល់ទណ្ឌិតរូបនេះ នៅក្នុងរយៈពេលនៃការជាប់ពន្ធនាគាររបស់គាត់ឡើយ។ សហព្រះរាជអាជ្ញាក៏បានគិតទុកផងដែរ អំពីការដែលគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ អាចចុះទៅធ្វើការត្រួតពិនិត្យពន្ធនាគារនានាជាទៀងទាត់ នៅក្នុងទូទាំងប្រទេសកម្ពុជា ដែលក្នុងនោះរួមមាន ពន្ធនាគារខេត្តកណ្ដាលផងដែរ។

យោងចំណារ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣របស់ **ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី** និងជា **រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** យល់ព្រមក្នុងការសម្របសម្រួលបញ្ជូន **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** ពីមន្ទីរឃុំឃាំង អវតក ទៅកាន់ពន្ធនាគារខេត្តកណ្ដាល។

នៅថ្ងៃ០៦ ខែមិថុនា ឆ្នាំ២០១៣ **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** ត្រូវបានបញ្ជូនទៅកាន់ពន្ធនាគារខេត្តកណ្ដាល ដើម្បីអនុវត្តទោសជាប់ពន្ធនាគារដែលនៅសល់របស់គាត់ពីថ្ងៃនេះតទៅ។